# ទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដោះស្រាយបញ្ហាកំពុងកើតឡើង

( Pragmatism )

**ដោយបណ្ឌិត វង់ សំអូន**
**ជំនួយការខុទ្ទកាល័យរាជបណ្ឌិត្យសភាកម្ពុជា**

ទស្សនវិទូក្រុមនេះបានប្រើប្រាស់*គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះតែប៉ុណ្ណោះ* ក្នុងការសិក្សាស្វែងរកចម្លើយ ឬដោះស្រាយបញ្ហាទាំងឡាយណាដែលបានកើតមានឡើងចេញពីសកម្មភាពណាមួយដែលត្រូវបានគេអនុវត្ត ឬប្រព្រឹត្តនៅក្នុងសង្គម។ នៅក្នុងការកំណត់បញ្ហាដើម្បីធ្វើការសិក្សាស្រាវជ្រាវ ទស្សនវិទូក្រុមនេះ បានផ្តោតសំខាន់លើបញ្ហា៖

(១) បញ្ហាទាំងឡាយណាដែលជា***លទ្ធផលបានកើតចេញពីការប្រព្រឹត្ត ឬលទ្ធផលកើតចេញពីទង្វើអ្វីមួយ***។ រាល់ទង្វើ ឬការប្រព្រឹត្តរបស់មនុស្ស ឬបាតុភូតធម្មជាតិទាំងអស់សុទ្ធតែទទួលបាននូវផល។ គ្រាន់តែផល ឬលទ្ធផលទាំងនោះអាចមានលក្ខណៈជាវិជ្ជមាន ឬអវិជ្ជមានតែប៉ណ្ណោះ (ដោយមិនបានផ្តោតលើបញ្ហា ឬផលទាំងឡាយណា ដែលនឹងកើតមានឡើងនាពេលអនាគតនោះឡើយ) ហើយផលវិជ្ជមាន ឬអវិជ្ជមានទាំងអស់នោះ ត្រូវបានអ្នកសិក្សាស្រាវជ្រាវធ្វើការសិក្សាស្រាវជ្រាវដោយមានវត្ថុបំណងផ្សេងៗដូចជា៖ នៅក្នុងករណីលទ្ធផលទាំងនោះមានលក្ខណៈអវិជ្ជមាន បញ្ហាទាំងនោះត្រូវបានអ្នកសិក្សាស្រាវជ្រាវសិក្សាដើម្បីរកមូលហេតុ ផលប៉ះពាល់ ឬជាតុចូលផ្សេងៗដែលបង្កហេតុចេញពីការប្រព្រឹត្ត ការអនុវត្ត ឬហេតុការណ៍ទាំងឡាយណាដែលកំពុងកើតមានឡើង។

ឧទាហរណ៍ ការប្រើប្រាស់កម្មវិធីបញ្ញាសប្បនិម្មិតបានរីកសាយភាយកាន់តែខ្លាំងឡើងខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ តាមរយៈការប្រើប្រាស់កម្មវិធីបញ្ញាសប្បនិម្មិតនេះ មានការយល់ឃើញរបស់បញ្ញាជន ក៏ដូចជាអ្នកប្រើប្រាស់មួយចំនួនបានលើកឡើងថា ការប្រើប្រាស់កម្មវិធីបញ្ញាសប្បនិម្មិតបានផ្តល់ទាំងគុណសម្បត្តិ និងគុណវិប្បត្តិ ជាពិសេសនៅក្នុងជួរកងទ័ព។ នៅពេលធ្វើសង្គ្រាម វាអាចបង្កការសម្លាប់រង្គាលដល់ជនស៊ីវីលដែលមិនមានទោសកំហុស ពីព្រោះអាវុធដែលប្រើបញ្ញាសប្បនិម្មិតមិនអាចញែក ឬបែងចែករវាងជនស៊ីវិល ឬទាហ៊ានបានទេនៅពេលធ្វើសង្គ្រាម) ឬសិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវលែងប្រើប្រាស់ការសិក្សាស្វែងយល់ដោយខ្លួនឯង ប៉ុន្តែបានប្រើប្រាស់កម្មវិធីបញ្ញាសប្បនិម្មិតដើម្បីបង្កើត ឬស្វែងរកចម្លើយជំនួសវិញ (ការធ្វើបែបនេះអាចធ្វើឱ្យខួរក្បាល់របស់មនុស្សស្ពឹកនៅពេលណាមួយ)។ ក្នុងករណីនេះ អ្នកសិក្សាស្រាវជ្រាវអាចទាញយកបញ្ហាដែលកើតចេញពីសកម្មភាពនៃការប្រើប្រាស់កម្មវិធីបញ្ញាសប្បនិម្មិត ″ការសិក្សាពីយន្តការនៃការប្រើប្រាស់កម្មវិធីបញ្ញាសប្បនិម្មិតក្នុងការជំរុញដល់ការលូតលាស់បញ្ហារបស់សិស្ស″ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ។ យោងតាមធម្មជាតិនៃបញ្ហានេះ វាមានទំនោរទៅរកក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវ ដើម្បីដោះស្រាវបញ្ហាដែលកំពុងកើតឡើងតាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះតែប៉ុណ្ណោះ។

(២) ផ្តោតសំខាន់លើ***បញ្ហាជាចម្បង***។ ទស្សនវិទូក្រុមនេះបានជឿជាក់ថាការពិតគឺអ្វីដែលកំពុងកើតឡើងនៅពេលនោះ។ ដូច្នេះការស្វែងរកចម្លើយនៃការពិតគឺត្រូវមើលបញ្ហាដែលកំពុងកើត

មានឡើងនៅពេលនោះ ហើយនោះជាបញ្ហា ឬប្រធានបទស្នូលដែលអ្នកសិក្សាស្រាវជ្រាវត្រូវសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅដើម្បីរកដំណោះស្រាយសមស្របណាមួយ។ ការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គម ជាពិសេសប្រភេទការសិក្សាស្រាវជ្រាវគរុសភា (Academic Research) អ្នកសិក្សាស្រាវជ្រាវអាចបង្កើតប្រធានបទការសិក្សាស្រាវជ្រាវ ដោយទាញយកបញ្ហាដែលកំពុងកើតមានឡើងនេះធ្វើជាប្រធានបទនៅក្នុងការសិក្សាស្រាវជ្រាវ(បញ្ហាមិនមែនកើតមកពីការគិតចង់ធ្វើការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាស្រាវជ្រាវនោះទេប៉ុន្តែត្រូវតែជាបញ្ហាពិតប្រាកដ ឬបញ្ហាស្នូលដែលកំពុងកើតមានឡើង)។

ឧទាហរណ៍ គេសង្កេតឃើញថា នៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ មនុស្សភាគច្រើនមិនថាក្មេងជំទង មនុស្សចាស់ រាស្ត្រ មន្ត្រីស៊ីវិល យោធា ពេទ្យ មេធាវី ឬគ្រូបង្រៀន។ល។ ជានិច្ចកាលបានទទួលទានសុរាហួសកម្រិត និងជាប្រចាំ។ ការទទួលទានតាមចិត្តចង់ ឬមិនតាមចិត្តចង់បែបនេះបានបង្កបញ្ហាជាច្រើននៅក្នុងសង្គមដូចជា៖ គ្រោះថ្នាក់ចរាចរណ៍ដោយសារបើកបរនៅពេលស្រវឹង ប្រឈមនឹងជំងឺផ្សេងៗ (ទឹកនោមផ្អែម លើសឈាម ក្រិនថ្លើម) ប៉ះពាល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ (ចំណាយប្រាក់លើសុរា ចំណាយប្រាក់ព្យាបាលជម្ងឺដែលកើតចេញពីការផឹកសុរា គ្រូពេទ្យរវល់តែមើលអ្នកជម្ងឺសុរា) បាត់បង់សតិ និងបង្កគ្រោះថ្នាក់ដល់អ្នកដ៏ទៃ បង្កើតអំពើហឹង្សានៅក្នុងគ្រួសារ និងនៅក្នុងសង្គម ឈានដល់ការបង្កអំពើអបាយមុខ (កាប់ចាក់ ឆក់ លួចប្លន់ ញៀនថ្នាំ និងញៀនល្បែង) ឬស្លាប់មុនអាយុជាដើម (គ្រោះថ្នាក់ចរាចរណ៍ ឬកើតជម្ងឺដែលបណ្ដាលមកពីសុរា)។

ទាំងអស់នេះជាបញ្ហាចម្បងដែលកំពុងកើតមានឡើងនៅក្នុងសង្គមនាពេលបច្ចុប្បន្ន និងបានទាមទារឱ្យអ្នកសិក្សាស្រាវជ្រាវធ្វើការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ ឬស្វែងរកបុព្វហេតុដើម្បីរិះរកវិធីដោះស្រាយ ទប់ស្កាត់ កាត់បន្ថយ ឬបញ្ឈប់បញ្ហាដែលកំពុងកើតឡើងនេះ។ អ្នកសិក្សាស្រាវជ្រាវអាចលើកយកបញ្ហាកំពុងកើតមានឡើងនេះ "ការប្រើប្រាស់ទស្សនទានពុទ្ធសាសនានៅក្នុងការជំរុញដល់ការកាត់បន្ថយការសេពគ្រឿងស្រវឹងរបស់ស្រទាប់យុវជន" ធ្វើជាប្រធានបទដើម្បីសិក្សាស្រាវជ្រាវ។ តាមធម្មជាតិនៃបញ្ហានេះបានបង្ហាញថា វាមានទំនោរទៅរកក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាទាំងឡាយណាដែលកំពុងកើតមានឡើង តាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះតែប៉ុណ្ណោះ។

(៣) ការស្វែងរកដំណោះស្រាយលើបញ្ហាកំពុងកើតឡើងដោយផ្ដោតលើ***វិធីសាស្ត្រចម្រុះ***។ នៅក្នុងការសិក្សាស្រាវជ្រាវ ដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាទាំងឡាយណាដែលកំពុងកើតមានឡើង ទស្សនវិទូក្រុមនេះពុំបានផ្ដោតលើការសិក្សាស្រាវជ្រាវដោយផ្អែកលើកម្មវត្ថុវិស័យណាមួយ ឬប្រធានវិស័យណាមួយនោះទេប៉ុន្តែ ទស្សនវិទូក្រុមនេះបានប្រើប្រាស់វិធីសាស្ត្រចម្រុះ ឬគោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះ (Pluralistic) ដោយរួមបញ្ចូលគ្នារវាងគោលវិធីសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យ និងគោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ។

ការសិក្សាស្រាវជ្រាវ ដោយប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះដើម្បីសិក្សាលើបញ្ហាទាំងឡាយណាដែលកំពុងកើតមានឡើងនៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ អ្នកសិក្សាស្រាវជ្រាវ

មានសិទ្ធសេរីភាពនៅក្នុងការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ ឬបច្ចេកទេសផ្សេងៗនៅក្នុងការប្រមូលទិន្នន័យពីក្រុមគោលដៅ និងការវិភាគទិន្នន័យទៅតាមធម្មជាតិបញ្ហាដែលកំពុងកើតមានឡើង។ អ្នកសិក្សាស្រាវជ្រាវ អាចប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យមុន និងតាមដោយវិធីសាស្ត្រស្រាវជ្រាវគុណវិស័យក្នុងករណីអ្នកសិក្សាស្រាវជ្រាវចង់យកលទ្ធផល ដែលទទួលបានពីការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវគុណវិស័យ ដើម្បីពន្យល់បន្ថែមលើលទ្ធផលទទួលបានពីការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ ឬការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ និងវិធីសាស្ត្រស្រាវជ្រាវគុណវិស័យតំណាលគ្នា ក្នុងករណីអ្នកសិក្សាស្រាវជ្រាវចង់ធ្វើការប្រៀបធៀបរវាងលទ្ធផលទទួលបានពីការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ និងការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវគុណវិស័យ ឬប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវគុណវិស័យមុន និងវិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យតាមក្រោយក្នុងករណីអ្នកសិក្សាស្រាវជ្រាវ ចង់យកលទ្ធផលដែលទទួលបានពីការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ ដើម្បីបំពេញបន្ថែមលើលទ្ធផលដែលទទួលបានពីវិធីសាស្ត្រស្រាវជ្រាវគុណវិស័យ។

ឧទាហរណ៍ នៅក្នុងសង្គមនាពេលបច្ចុប្បន្ន ជាពិសេសនៅក្នុងប្រទេសតតិយលោក គេសង្កេតឃើញថា មនុស្សភាគច្រើនចង់មានចង់បានដោយមិនចង់ធ្វើការងារ ឬមិនចង់ប្រឹងប្រែងរៀនសូត្រ។ គំនិត ឬបញ្ហានេះបានកំពុងរីករាលដាល និងបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្រទាប់យុវជនដែលជាទំពាំងស្នងឫស្សី និងអាចធ្វើឱ្យពួកគេក្លាយជាទំពាំងពុកនៅពេលណាមួយនាពេលអនាគត។ អ្នកសិក្សាស្រាវជ្រាវអាចទាញយកបញ្ហាដែលកំពុងកើតមានឡើងនេះ "យន្តការនៃការអនុវត្តក្រមសីលធម៌ការងាររបស់មន្ត្រីរាជការ" ធ្វើជាប្រធានបទក្នុងការសិក្សាស្រាវជ្រាវដើម្បីរកដំណោះស្រាយ។ យោងតាមធម្មជាតិនៃបញ្ហានេះ វាមានទំនោរទៅក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតមានឡើងតាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះ។

(៤) ផ្តោតលើ***ការប្រតិបត្តិជាក់ស្តែង***។ ទស្សនវិទូក្រុមនេះមានជំនឿថា រាល់បញ្ហា ឬប្រធានបទនៃការសិក្សាស្រាវជ្រាវគឺត្រូវទាញចេញ ឬបង្កើតចេញពីការប្រតិបត្តិជាក់ស្តែងតែប៉ុណ្ណោះ។ តាមរយៈការអនុវត្ត ឬការប្រតិបត្តិជាក់ស្តែងអាចធ្វើឱ្យប្រតិបត្តិករទទួលបានផលតាមបំណងឬមិនតាមបំណង។ ក្នុងករណីប្រតិបត្តិករមិនទទួលបានផលតាមបំណង ឬតាមផែនការដែលបានគ្រោងទុក ពួកគេត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងរកមូលហេតុ និងដំណោះស្រាយផ្សេងៗ។

ឧទាហរណ៍ នៅក្នុងសង្គមនាពេលបច្ចុប្បន្ន គេសង្កេតឃើញថា ចំណីអាហារភាគច្រើនបានផ្សំឡើងដោយសារជាតុគីមី ឬប្រើប្រាស់សារជាតុគីមីដើម្បីរក្សាទុកឱ្យបានរយៈពេលយូរ។ ការប្រើប្រាស់សារជាតុគីមីដោយខ្វះបច្ចេកទេស ឬដោយមិនមានការត្រួតពិនិត្យ និងតាមដានច្បាស់លាស់នៅក្នុងចំណីអាហារបានបង្កផលប៉ះពាល់ដល់សុខភាពរបស់អ្នកបរិភោគដោយផ្ទាល់ (បង្កជាជំងឺផ្សេងៗ) និងប៉ះពាលដល់ការលូតលាស់ផ្នែកសេដ្ឋកិច្ចរបស់គ្រួសារ និងជាតិដោយប្រយោល (ធ្វើឱ្យបាត់បង់កំលាំងពលកម្ម និងចំណាយថវិកាលើការព្យាបាលជំងឺដែលបង្កដោយការបរិភោគចំណីអាហារមានសារជាតុគីមីហួសកម្រិត)។

អ្នកសិក្សាស្រាវជ្រាវអាចទាញយកបញ្ហា "ការសិក្សាពីសុវត្ថិភាពនៃការបរិភោគចំណីអាហារ" ធ្វើជាប្រធានបទក្នុងការសិក្សាស្រាវជ្រាវដើម្បីស្វែងរកដំណោះស្រាយ រកវិធីទប់ស្កាត់ វិធីកាត់បន្ថយ ឬបញ្ឈប់បញ្ហាទាំងនោះមិនឱ្យរីករាលដាល ឬបន្តការកើតឡើងជាបន្តទៀត។ យោងតាមធម្មជាតិនៃបញ្ហានេះ វាជាបញ្ហាជាក់ស្តែង និងមានទំនោរទៅរកក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាកំពុងកើតមានឡើងតាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបចម្រុះ។

**ជាតុគោលរបស់ក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាកំពុងកើតឡើង**




ជារួម *រាល់បញ្ហា ឬប្រធានបទនៃការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គមទាំងអស់ត្រូវបានទាញចេញពីក្រុមទស្សនវិទូណាមួយនៅក្នុងចំណោមក្រុមទស្សវិទូទាំងបួន*។ ដូច្នេះអ្នកសិក្សាស្រាវជ្រាវជាពិសេសការស្រាវជ្រាវគរុសភា អាចទាញយកបញ្ហាដើម្បីបង្កើតជាប្រធានបទក្នុងការសិក្សាស្រាវជ្រាវចេញពីក្រុមទស្សនវិទូណាមួយក៏បាន។ អ្នកសិក្សាស្រាវជ្រាវទាញយកបញ្ហាដើម្បីបង្កើតប្រធានបទក្នុងការផ្ទៀងផ្ទាត់ទ្រឹស្តីចេញក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីធ្វើការផ្ទៀងផ្ទាត់ទ្រឹស្តី បង្កើតប្រធានបទដើម្បីសិក្សាពីនយោបាយ អំណាច វិសមភាព ឬភាពអយុត្តិធម៌ចេញក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីផ្លាស់ប្តូរ បង្កើតប្រធានបទដើម្បីសិក្សាពីបញ្ហាណាមួយដែលកំពុងកើតឡើងនាពេលបច្ចុប្បន្នចេញពីក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវ ដើម្បីដោះស្រាយបញ្ហាកំពុងកើតមានឡើង ឬបង្កើតប្រធានបទក្នុងការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មីចេញពីក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មី។

ក្នុងករណីនេះ *អ្នកសិក្សាស្រាជ្រាវអាចបញ្ចៀសការសួរសំណួរ "តើខ្ញុំគួរសិក្សាលើប្រធានបទអ្វី? តើបញ្ហាការសិក្សាស្រាវជ្រាវនោះគឺអ្វី? តើបញ្ហាក្នុងប្រធានបទនេះអាចសិក្សាស្រាវជ្រាវបានដែរឬទេ? តើការសិក្សានេះប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវប្រភេទណា?។" ពីព្រោះបញ្ហាទាំងអស់នៅក្នុងប្រធានបទ គឺត្រូវបានទាញពីក្រុមទស្សនវិទូណាមួយក្នុងចំណោមក្រុមទស្សនវិទូទាំងបួនប្រភេទ ហើយគោលវិធីសិក្សាស្រាវជ្រាវក៏ដើរទៅតាមនោះដែរ* (មិនមែនតាមការគិត ឬការនឹកឃើញ និងចង់

បានរបស់អ្នកសិក្សាស្រាវជ្រាវនោះទេ)។ ចំណុចនេះជាចំណុចដំបូងបង្អស់ និងជាចំណុចចម្បងដែលអ្នកសិក្សាស្រាវជ្រាវត្រូវរកឱ្យឃើញ និងឆ្លើយឱ្យរួច មុននឹងបន្តធ្វើការសិក្សាស្រាវជ្រាវ ***បើមិនដូច្នោះទេការសិក្សាស្រាវជ្រាវនោះ នឹងប្រាសចាកគោលការណ៍វិទ្យាសាស្ត្រ និងក្រមសីលធម៌***។

**ជាតុគោលរបស់ក្រុមទស្សនវិទូទាំងបួនប្រភេទ**




## ឯកសារយោង


Babbie, E. (1995). The practice of social research (7th Ed.). Wadsworth publishing, California, USA

Creswell, W.J., & Creswell, D.J. (2018). Research Design: Qualitative, quantitative, and mixed methods approach. (5th Ed.). SAGE publication

Cronk, C.B. (2008). How to use SPSS: A step-by-step guide to analysis and interpretation. (5th Ed.). Pyrezak publishing, California, USA

Kerlinger, N.F. & Lee, B.H. (2000). Foundation of behavioral research (4th Ed.). Thomson learning, USA